00640289

E25/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** PUBLIC-002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E25 | 00640257-00640259 | 27 January 2011 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| **មូលហេតុនៃការកែតម្រូវ៖** |
|---|
| សុំបន្ថែមមួយឃ្លា នៅលើទំព័រទី២ |

| **សេចក្ដីលម្អិតនៃការកែតម្រូវ៖** |
|---|
| សុំបន្ថែមឃ្លា "ឆ្លើយតបទៅនឹង សំណើរបស់ក្រុមមេធាវីលោក ខៀវ សំផន និងជាការកំណត់ជាទូទៅអំពីនីតិវិធីនៃការដាក់ពាក្យសុំរបស់ក្រុមមេធាវីការពារក្ដីទាំងអស់ ។" នៅលើទំព័រទី២ |

ភាគីស្នើសុំ៖ T-C ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 01 / 2011
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

**បានឃើញ** នូវសំណើសុំរបស់ក្រុមមេធាវីលោក ខៀវ សំផន ដែលបានស្នើសុំចូលមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក និងចូលមើលសំណុំរឿងលេខ ០០២ (“សំណើ”)[2] ។

<u>**ឆ្លើយតបទៅនឹង** សំណើរបស់ក្រុមមេធាវីលោក ខៀវ សំផន និងជាការកំណត់ជាទូទៅអំពីនីតិវិធីនៃការដាក់ពាក្យសុំរបស់ក្រុមមេធាវីការពារក្តីទាំងអស់ ។</u>

Formatted: Font: (Default) Khmer Kep

**អនុលោមតាម** វិធាន ៨៥ នៃវិធានផ្ទៃក្នុង និងវិធាន ៩ នៃវិធានសម្រាប់គ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះ ឬប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“វិធានស្តីពីការគ្រប់-គ្រងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក”)។

## ហេតុដូច្នេះ

**សូមណែនាំថា** សមាជិកក្រុមមេធាវីការពារក្តីនឹងត្រូវបានអនុញ្ញាតឲ្យចូលជួបជនជាប់ចោទនៅមន្ទីរឃុំឃាំង អនុលោមតាមវិធាន ៩.១៨ នៃវិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។

អង្គភាពគាំពារការការពារក្តីត្រូវជូនដំណឹងជាបន្ទាន់ដល់ប្រធានមន្ទីរឃុំឃាំង តាមរយៈមន្ត្រីសម្របសម្រួលមន្ទីរឃុំឃាំងនូវសមាជិកថ្មី ឬសមាជិកណាមួយដែលបានលាឈប់ពីក្រុម។ ការជូនដំណឹងនេះត្រូវចម្លងជូន

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9។

[2] “សំណើសុំពិនិត្យមើលសំណុំរឿង ០០២ និងចូលក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក” ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E7 ។ “សំណើសុំពិនិត្យមើលសំណុំរឿង ០០២ និងចូលក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក” ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E8 (សំណើ) ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C